3. The tribunal shall address any such objection as a preliminary question apart from the merits of the claim. The disputing parties shall be given a reasonable opportunity to present their views and observations to the tribunal. If the tribunal decides that the claim is manifestly without merit, or is otherwise not within the jurisdiction or competence of the tribunal, it shall render an award to that effect.

4. The tribunal may, if warranted, award the prevailing party reasonable costs and fees incurred in submitting or

CERTIFIED COPY DEPUTY SECRETARY GENERAL THE ASEAN SECRETARIAT asean

opposing the objection. In determining whether such an award is warranted, the tribunal shall consider whether either the claim or the objection was frivolous or manifestly without merit, and shall provide the disputing parties a reasonable opportunity to comment.

5. Unless the disputing parties otherwise agree, the tribunal shall determine the place of arbitration in accordance with the applicable arbitration rules, provided that the place shall be in the territory of a State that is a party to the New York Convention.

6. Where an investor claims that the disputing Party has breached Article 9 (Expropriation and Compensation) by the adoption or enforcement of a taxation measure, the disputing Party and the non-disputing Party shall, upon request from the disputing Party, hold consultations with a view to determining whether the taxation measure in question has an effect equivalent to expropriation or nationalisation. Any tribunal that may be established pursuant to this Section shall accord serious consideration to the decision of both Parties under this Paragraph.

7. If both Parties fail either to initiate consultations referred to in Paragraph 6, or to determine whether such taxation measure has an effect equivalent to expropriation or nationalisation within the period of 180 days from the date of the receipt of request for consultation referred to in Article 19 (Consultations), the disputing investor shall not be prevented from submitting its claim to arbitration in accordance with this Section.

Article 26
Transparency of Arbitral Proceedings

1. Subject to Paragraphs 2 and 3, the disputing Party may make publicly available all awards and decisions produced by the tribunal.

CERTIFIED COPY

2. Any of the disputing parties that intend to use information designated as confidential information in a hearing shall so advise the tribunal. The tribunal shall make appropriate arrangements to protect the information from disclosure.

3. Any information specifically designated as confidential that is submitted to the tribunal or the disputing parties shall be protected from disclosure to the public.

4. A disputing party may disclose to persons directly connected with the arbitral proceedings such confidential information as it considers necessary for the preparation of its case, but it shall require that such confidential information is protected.

5. The tribunal shall not require a Party to furnish or allow access to information the disclosure of which would impede law enforcement or would be contrary to the Party's law protecting Cabinet confidences, personal privacy or the financial affairs and accounts of individual customers of financial institutions, or which it determines to be contrary to its essential security.

6. The non-disputing Party shall be entitled, at its cost, to receive from the disputing Party a copy of the notice of arbitration, no later than 30 days after the date that such document has been delivered to the disputing Party. The disputing Party shall notify all other Parties of the receipt of the notice of arbitration within 30 days thereof.

Article 27
Governing Law

1. Subject to Paragraphs 2 and 3, when a claim is submitted under Article 20 (Claim by an Investor of a Party), the tribunal shall decide the issues in dispute in accordance with this Agreement, any other applicable agreements between the Parties, any relevant rules of international law

CERTIFIED COPY
DEPUTY SECRETARY GENERAL THE ASEAN SECRETARIAT

applicable in the relations between the Parties, and, where applicable, any relevant domestic law of the disputing Party.

2. The tribunal shall, on its own account or at the request of a disputing party, request a joint interpretation of any provision of this Agreement that is in issue in a dispute. The Parties shall submit in writing any joint decision declaring their interpretation to the tribunal within 60 days of the delivery of the request. Without prejudice to Paragraph 3, if the Parties fail to issue such a decision within 60 days, any interpretation submitted by a Party shall be forwarded to the disputing parties and the tribunal, which shall decide the issue on its own account.

3. A joint decision of the Parties, declaring their interpretation of a provision of this Agreement shall be binding on a tribunal, and any decision or award issued by a tribunal must be consistent with that joint decision.

Article 28
Awards

1. Where a tribunal makes a final award against either of the disputing parties, the tribunal may award, separately or in combination, only:

(a) monetary damages and any applicable interest; and

(b) restitution of property, in which case the award shall provide that the disputing Party may pay monetary damages and any applicable interest in lieu of restitution.

2. A tribunal may also award costs and attorney's fees in accordance with this Section and the applicable arbitration rules.

3. A tribunal may not award punitive damages.

CERTIFIED COPY

4. An award made by a tribunal shall be final and binding upon the disputing parties. An award shall have no binding force except between the disputing parties and in respect of the particular case.

5. Subject to Paragraph 6 and the applicable review procedure for an interim award, a disputing party shall abide by and comply with an award without delay.[15]

6. A disputing party may not seek enforcement of a final award until:

(a) in the case of a final award under the ICSID Convention:

(i) 120 days has elapsed from the date the award was rendered and no disputing party has requested revision or annulment of the award; or

(ii) revision or annulment proceedings have been completed;

(b) in the case of a final award under the ICSID Additional Facility Rules, the UNCITRAL Arbitration Rules, or the rules selected pursuant to Article 21.1(e) (Submission of a Claim):

(i) 90 days have elapsed from the date the award was rendered and no disputing party has commenced a proceeding to revise, set aside, or annul the award; or

(ii) a court has dismissed or allowed an application to revise, set aside, or annul the award and there is no further appeal.

7. Each Party shall provide for the enforcement of an award in its territory.

[15] The Parties understand that there may be domestic legal and administrative processes that need to be observed before an award can be complied with.

CERTIFIED COPY
SECRETARY-GENERAL, THE ASEAN
asean

ត ទៅរាជកិច្ច លេខ ៨៨

ព្រះរាជក្រឹត្យ

នស/រកត/០៧១០/៥៩០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្មូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ "ធិបឌិន្ទ" ចំពោះ :

១- ឯកឧត្តម គឹម ណី

២- លោក តួង វិចិត្រ

ខ/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ "សេនា" ចំពោះ :

១- លោក សុន្ធ សាងបុណ្យ

២- លោក មិញ ជា

៣- កញ្ញា ឈុត កន្យា

៤- លោក យ៉ាន់ ទ៉ាន់ជីលុច

៥- លោក សាំង ឃួរ

៦- លោក ឈឹង គីរុណ

៧- លោកស្រី ហ៊ាន ម៉ាណី



ក/គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ "អស្សឫទ្ធិ" ចំពោះ ៖

១. លោក ព្រហ្ម ច័ន្ទមុនី

២. លោក តុន គន្ធ

៣. លោកស្រី ពុំ ស្យាណូ

៤. លោក សុខ សុជាតិ

៥. លោក សេង ពិសិដ្ឋ

៦. លោក ញ៉ឹក ថាក់

៧. លោកស្រី ញៀម ដាវី

៨. លោកស្រី ឈឿម ចិន្តា

៩. លោក យឹម សំណាង

១០. លោក នុយ សារិន

១១. លោកស្រី នង់ ម៉ុននៅ

១២. លោកស្រី នូ ឈិន

១៣. លោក គួយ ចន្ធា

១៤. លោក ពៅ វុត្ថា

១៥. លោក គា ធ្រី

១៦. លោក សំអៀន ម៉ារ៉ាឌី

១៧. លោក អ៊ុច ទ៊ាន់ឌី

១៨. កញ្ញា សាន ចាន់ប្រស្នា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

១៩- លោក ហ៊ួយ វ៉ាន់ឌី

២០- លោក កេត ជិន្តរ៉ែន

២១- លោក នៃ ម៉ានិល

២២- លោក លឹង សេង

២៣- លោកស្រី សំ សុផល្លីស

២៤- លោក ហេង ស្មើ

២៥- លោក ហួត ប្រាកដ

២៦- លោក លីន សាមិត

២៧- លោកស្រី សុវណ្ណ រំដួល

២៨- លោក ប្រាក់ ដុល្លីន

២៩- លោក ឈឹម ស៊ុណា

៣០- លោក ស៊ិន ណារ័ត្ន

៣១- លោក ហួក ឌីណារ៉ូ

៣២- លោក សេង សម្បត្តិ

៣៣- លោកស្រី ឈឹម ចំន្ទចត្តី

៣៤- លោកស្រី ឈឹម សំពិសី

៣៥- លោក សុខ ភូជាធីរៈ

៣៦- លោក ប៊ី សុក្របណ្ឌិត

៣៧- លោក ពុធ សំអឿន

៣៨. លោកស្រី អ៊ុំ ប្រុណង៍

៣៩. លោក គីម សុឃីណា

៤០. លោក ឡុង ចាន់ហេង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១០

៣.ល.១០០៧.៤០៣

លេខ: ៧៤៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១០

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ឃុន ម៉ិងកេន

ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា នាសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី២ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: តែងតាំងឯកឧត្តម **នួន ម៉ុត** ជាទីប្រឹក្សាអមអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់នីតិកាលទី២ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

៣.ល.១០១១.៩៤០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០

លេខ: ៧៧០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល
សុខ ចិនតេន

ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៦៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងឯកឧត្តម **តូច សុខុន** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា២ : សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣.៧.១០១១.៧៩១

លេខៈ ៧៧៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញៈថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១០
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០

ហត្ថលេខា: ប៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៥ រូប

មានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិ មាតុភូមិនាពេលកន្លងមក

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

១-ឧត្តមសេនីយ៍ឯក	សំ	ចណ្ណថន	អត្តលេខ ០០០២០៥
២-ឧត្តមសេនីយ៍ឯក	មាស	សាម៉ន	អត្តលេខ ០០០០៧៩
៣-ឧត្តមសេនីយ៍ឯក	ស៊ុំ	សំណាង	អត្តលេខ ០០០០៧៤
៤-ឧត្តមសេនីយ៍ឯក	ចៅ	ភិរុណ	អត្តលេខ ០០០០៧៥
៥-ឧត្តមសេនីយ៍ឯក	ឈឹម	សុខន្តិ	អត្តលេខ ០០០០៦៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល. ១០១១. ៩៩០

លេខ: ៧៩៤ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១០

ដើម្បីចម្លងចែកជូន

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំខេត្តកោះកុង ចំនួន០៥រូប មានស្នាដៃនិងគុណបំណាច់ធំៗជាច្រើនចំពោះជាតិមាតុភូមិ ដោយបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការអភិវឌ្ឍន៍ខេត្តកោះកុង ទទួលបានលទ្ធផលល្អ ។

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឯកឧត្តម ប៊ុន លើត
២-ឯកឧត្តម ភាយ សំរួម
៣-ឯកឧត្តម អ៊ុន ឆាលី
៤-លោកស្រី អេង គីមនាង

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

លោក ជុំ យុហៀន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣.ល. ១០១១. ៩៩១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១០

លេខៈ ៧៨៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ជិនកេង

ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ដែលបានបរិច្ចាគធនធានចូលរួមចំណែកកសាងក្នុងវិស័យព្រះពុទ្ធសាសនា
និងសង្គមកិច្ច នៅខេត្តព្រៃវែង

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៖

១- ព្រះតេជគុណ **អ៊ុង ស៊ីណាត**
២- លោក **សយ សុត**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៧.១០១១.៩៩៤ **នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១០

លេខ៖ ៧៩៥ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១១០/៨៧៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី
ត្រាស់ព្រះរាជឱង្ការ

ចំពោះ

លោកជំទាវ លោកស្រី អស់លោកជាមន្ត្រីរាជការ និងសប្បុរសជន
ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនរួមចំណែកកសាងអាគារសាកលវិទ្យាល័យបាត់ដំបង

នូវ

ក. គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :

លោកជំទាវ ញៀម សាខន ស ខេង

ខ. គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :

១- លោកជំទាវ យូ យ៉ុម ម៉ៅ ស៊ុនលី
២- លោកជំទាវ ម៉េង សោភា ផាត់ ប៊ុន

គ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១- លោក ស សុខា
២- លោកស្រី កែ សួនសុភី ស សុខា
៣- លោក ឈឿន កុសលធីរៈ
៤- លោកស្រី ស ស៊ីណា ឈឿន កុសលធីរៈ

ឃ. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១- លោក ស វឌ្ឍា
២- លោក គល់ សុផាត

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល. ១០១១. ៥៩៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១០

លេខ: ៧៧៩ ច.ល
[illegible] សម្រាប់ចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

[illegible] ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងចេនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានដំឡើងឋានន្តរស័ក្តិ ថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជាកិច្ចបច្ឆាមរណៈ ជូនសពនាយទាហានជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ

- វរសេនីយ៍ឯក **ណែម រ៉េត** អត្តលេខ ០០២៥១៧

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.១០១១.៩៩៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១០

លេខ:៧៩៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ វិច្ឆិកា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៨៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ វត្ថុសិល្បៈបុរាណខ្មែរដែលត្រូវយកទៅតាំងពិព័រណ៍នៅបរទេស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

សម្រេច

មាត្រា ១.-

ត្រូវបានបង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យវត្ថុសិល្បៈបុរាណខ្មែរដែលត្រូវយកទៅតាំងពិព័រណ៍នៅបរទេស ដែលមានសមាសភាពដូចខាងក្រោម ÷

- រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ប្រធាន
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
- ឥស្សរជនដែលមានចំណេះដឹងជ្រៅជ្រះផ្នែកបេតិកភណ្ឌ អនុប្រធាន

- រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិកអចិន្ត្រៃយ៍
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាងក្រសួងទេសចរណ៍ សមាជិក

សមាសភាពជាក់ស្តែងរបស់គណៈកម្មាធិការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យវត្ថុសិល្បៈបុរាណខ្មែរដែលត្រូវយកទៅតាំងពិព័រណ៍នៅបរទេស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

មាត្រា ២.

គណៈកម្មាធិការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យវត្ថុសិល្បៈបុរាណខ្មែរដែលត្រូវយកទៅតាំងពិព័រណ៍នៅបរទេស មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ពិនិត្យ និងសម្រេចលើសំណើសុំយកវត្ថុសិល្បៈបុរាណខ្មែរទៅតាំងពិព័រណ៍នៅបរទេស
- សម្របសម្រួល និងទំនាក់ទំនងជាមួយភាគីបរទេស និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងដំណើរការរៀបចំតាំងពិព័រណ៍វត្ថុសិល្បៈបុរាណខ្មែរនៅបរទេស
- ពិនិត្យ និងសម្រេចលើកិច្ចព្រមព្រៀង កិច្ចសន្យា និងឯកសារចាំបាច់នានាសម្រាប់ការតាំងពិព័រណ៍ ដើម្បីធានាសុវត្ថិភាព និងលើកកំពស់តម្លៃវត្ថុសិល្បៈបុរាណខ្មែរ
- ពិនិត្យ និងសម្រេចលើវត្ថុសិល្បៈបុរាណខ្មែរដែលត្រូវយកទៅតាំងពិព័រណ៍នៅបរទេស និងលើតម្លៃធានារ៉ាប់រង
- ពិនិត្យតាមដានដំណើរការបច្ចេកទេស ការវេចខ្ចប់ ការដឹកជញ្ជូន និងការដាក់តាំងវត្ថុសិល្បៈបុរាណខ្មែរ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

មាត្រា ៣.

គណៈកម្មាធិការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យវត្ថុសិល្បៈបុរាណខ្មែរដែលត្រូវយកទៅតាំងពិព័រណ៍នៅបរទេស ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

មាត្រា ៤.

គណៈកម្មាធិការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យវត្ថុសិល្បៈបុរាណខ្មែរដែលត្រូវយកទៅតាំងពិព័រណ៍នៅបរទេស មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលស្ថិតនៅក្រោមក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

មាត្រា ៥.

គណៈកម្មាធិការ ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យវត្ថុសិល្បៈបុរាណខ្មែរដែលត្រូវយកទៅតាំងពិព័រណ៍នៅបរទេសមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

មាត្រា ៦.

គណៈកម្មាធិការ ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យវត្ថុសិល្បៈបុរាណខ្មែរដែលត្រូវយកទៅតាំងពិព័រណ៍នៅបរទេស មានប្រភពធនធានថវិកាមកពី ÷

- ថវិកាជាតិក្នុងកញ្ចប់ថវិការបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ហិរញ្ញប្បទានសហប្រតិបត្តិការពីក្នុង និងក្រៅប្រទេស ដែលផ្តល់ដោយអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានា។

មាត្រា ៧.

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៨.

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៨*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១២៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន០៨រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ កុដិ សាលាឆាន់ សាលាបុណ្យ របង ខ្លោងទ្វារ ធ្វើផ្លូវចូលនិងចាក់ដីក្នុងវត្ត ព្រមទាំងសមិទ្ធផលនានាជាច្រើនទៀត ស្ថិតនៅក្នុងវត្តគីរីមង្គលមានជ័យ (ស្រឡៅតូង) ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

ក-មេដាយមាសស្ថាបនាជាតិៈ

១-ព្រះតេជគុណ	ឈុន សុយុទ្រី	ចៅអធិការវត្ត	បច្ច័យចំនួន ១២.៥៧៨ ដុល្លារ
២-ព្រះតេជគុណ	ឈួន ចាន់រី		បច្ច័យចំនួន ១១.៩៧៤ ដុល្លារ
៣-ព្រះតេជគុណ	រស់ ចាន់		បច្ច័យចំនួន ១១.៨៦២ ដុល្លារ
៤-ព្រះតេជគុណ	ឈាន លី		បច្ច័យចំនួន ១០.៧៦៥ ដុល្លារ
៥-លោក	អ៊ុំ រដ្ឋា		ថវិកា ចំនួន ១១.៦១៣ ដុល្លារ
៦-អ្នកស្រី	សរ គឹមធន់		ថវិកា ចំនួន ១០.៨២២ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិៈ

១-អ្នកស្រី	សែម អេង	ថវិកា ចំនួន ៥.៧២៣ ដុល្លារ
២-អ្នកស្រី	សោម សំបូរ	ថវិកា ចំនួន ៥.៦១២ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១០
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១២៨.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ ប្រគេននិងជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ កុដិ សាលាឆាន់ សាលាបុណ្យ របង ខ្លោងទ្វារ ធ្វើផ្លូវចូល និងចាក់ដីក្នុងវត្ត ព្រមទាំងសមិទ្ធផលនានាជាច្រើនទៀត ស្ថិតនៅក្នុងវត្តគីរីមង្គលមានជ័យ (ស្រឡៅត្បូង) ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

១-ព្រះតេជគុណ	ម៉ក់ ជរ	បច្ច័យចំនួន ៨២.៦៧៤ ដុល្លារ
២-ព្រះតេជគុណ	ចែម មុនីចន្ថា	បច្ច័យចំនួន ៨១.៣១៥ ដុល្លារ
៣-លោក	ប៊ុន វីយុត	ថវិកាចំនួន ៨០.២១៣ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១២៩ . អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៨រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសាលាឆាន់ និងសមិទ្ធផលផ្សេងៗមួយចំនួនទៀត នៅវត្តសិរីចំប៉ា ឃុំមេព្រីង ស្រុកបាធាយ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសស្ថាបនាជាតិៈ

១-អ្នកស្រី	ញឹក ម៉ាស៊ី	សប្បុរសជន	ថវិកាចំនួន	២០.១០០ ដុល្លារ
២-ឧបាសិកា	និត្យ ឡៀង	សប្បុរសជន	ថវិកាចំនួន	១២.៥៣៥ ដុល្លារ
៣-ឧបាសិកា	អៀង អ៊ីមឡាយ	សប្បុរសជន	ថវិកាចំនួន	១២.៥៨៦ ដុល្លារ
៤-លោក	ឡៅ ហៀង	សប្បុរសជន	ថវិកាចំនួន	១២.៥៩៨ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិៈ

-លោក	ជុំ ធិ	សប្បុរសជន	ថវិកាចំនួន	៥.៥៥៨ ដុល្លារ

គ-មេដាយសំរឹទ្ធស្ថាបនាជាតិៈ

១-អ្នកស្រី	គីម ទ៊ាន់	សប្បុរសជន	ថវិកាចំនួន	៣.៥៦៨ ដុល្លារ
២-លោក	គួប ឡៀមចាន់យ៉ា	សប្បុរសជន	ថវិកាចំនួន	៣.៥១៥ ដុល្លារ
៣-លោក	ទូច ហ្គិចឡាង	សប្បុរសជន	ថវិកាចំនួន	៣.៥៣២ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ ដោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៧០.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន ចំនួន០៤ ដែលបានផ្តល់ថវិកា តាមរយៈអង្គការ School Aid Japan ជួយសាងសង់អគារសិក្សា នៅខេត្តពោធិ៍សាត់ ដូចមានរាយខាងក្រោម ៖

១-ក្រុមហ៊ុន WATAMI NO KAIGO បានផ្តល់ថវិកាចំនួន ៣២.០០០ ដុល្លារអាមេរិក ក្នុងការកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៣បន្ទប់ ជូនសាលាបឋមសិក្សារកាត ឃុំរកាត ស្រុកភ្នំក្រវាញ ។

២-ក្រុមហ៊ុន GAKKOU KENSETSU KIFUSHA បានផ្តល់ថវិកាចំនួន ៣២.០០០ ដុល្លារអាមេរិក ក្នុងការកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៣បន្ទប់ ជូនសាលាបឋមសិក្សាសេរីគន្ធា ឃុំតាលោ ស្រុកបាកាន ។

៣-ក្រុមហ៊ុន STOCK COMPANY BLAST បានផ្តល់ថវិកាចំនួន ៤៩.០០០ ដុល្លារអាមេរិក ក្នុងការកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ០១ខ្នង មាន០២បន្ទប់ ជូនសាលាបឋមសិក្សាឈើតុំ ឃុំឈើតុំ ស្រុកក្រគរ ។

៤-ក្រុមហ៊ុន STOCK COMPANY NIHON ZAITAKU បានផ្តល់ថវិកាចំនួន ៥១.០០០ ដុល្លារអាមេរិក ក្នុងការកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ០១ខ្នង មាន០២បន្ទប់ និងអណ្តូងទឹក០១ ជូនអនុវិទ្យាល័យអន្លង់ត្នោត ឃុំអន្លង់ត្នោត ស្រុកក្រគរ ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៧១ . អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន០៨រូប ដែលមានស្នាដៃល្អក្នុងការជួយអភិវឌ្ឍ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:

-លោក ហុក វីណារ៉ាត ប្រធានស្នាក់ការពន្ធដារ ស្រុកមង្គលបូរី

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ:

១-លោក ឌីម ណារិទ្ធ ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ស្រុកមង្គលបូរី

២-លោក គង់ សុខុន ប្រធានការិយាល័យ សង្គមកិច្ច ស្រុកមង្គលបូរី

៣-លោក សោ គាន់ សមាជិកក្រុមប្រឹក្សាស្រុកមង្គលបូរី

៤-លោក ណម យ៉ាន់ អនុប្រធានស្នាក់ការពន្ធដារ ស្រុកមង្គលបូរី

៥-អនុសេនីយ៍ឯក យ៉ន យ៉ុន អត្តលេខ ៤៤៥៣៨ អធិការរងនគរបាលស្រុកមង្គលបូរី

៦-អនុសេនីយ៍ឯក យ៉ត សុផល អត្តលេខ ០១៤១៩២ អធិការរងនគរបាលស្រុកមង្គលបូរី

៧-លោក ម៉ក់ គៀយ ប្រធានការិយាល័យ វប្បធម៌និងវិចិត្រសិល្បៈ ស្រុកមង្គលបូរី

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៣២ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធចំនួន២៩រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសការងារ

១-លោកវេជ្ជ.	គួច	ច័ន្ទថន	ផ្នែកវះកាត់មន្ទីរពេទ្យបង្អែក មិត្តភាពកម្ពុជា-ជប៉ុន ខេត្តបន្ទាយមានជ័យ
២-អនុសេនីយ៍ឯក	ម៉ែន	កល្យាណ	អត្តលេខ ៥៤១៩០ នាយរងប៉ុស្តិ៍ច្រកទ្វារបារិត ន.អន្តោប្រវេសន៍ក្រុម.ផ
៣-អនុសេនីយ៍ឯក	នាល	ពិសិដ្ឋ	អត្តលេខ ៥៤៤៨៦ នាយរងផ្នែកលិខិតឆ្លងដែន ន.ស្ថិតិលិខិតឆ្លងដែន ក្រុម.ផ
៤-លោក	ស៊ីវ	រ៉ាទុធ	អនុប្រធានស្នាក់ការពន្ធដារ ស្រុកមង្គលបូរី ខេត្តប.ជ
៥-លោក	ណយ	ប៊ុនសួន	អនុប្រធានការិយាល័យសំណង់សូរិយោដី ក្រុងសិរីសោភ័ណ ខេត្ត ប.ជ
៦-អនុសេនីយ៍ឯក	ដន	គន្ធារី	អត្តលេខ ១៧២៥៤ អនុក្រុមផ្តល់ទិដ្ឋាការ ន.អន្តោប្រវេសន៍ ក្រ.ម.ផ
៧-អនុសេនីយ៍ទោ	សៅ	សុភាព	អត្តលេខ ៥៤៨៤៨ មន្ត្រីនគរបាល ន.អន្តោប្រវេសន៍ ក្រ.ម.ផ
៨-អនុសេនីយ៍ទោ	សាទ	សម្ផស្ស	អត្តលេខ ៥៧៤៧៧ អនុក្រុមផ្តល់ទិដ្ឋាការ ន.អន្តោប្រវេសន៍ ក្រ.ម.ផ
៩-អនុសេនីយ៍ទោ	ជួប	ទ៉ាន់ឌី	អត្តលេខ ៥៦៣១៩ រងផ្នែកស្រាវជ្រាវបទល្មើសពន្ធ ន.ប្រឆាំងបទល្មើសសេដ្ឋកិច្ច
១០-អនុសេនីយ៍ទោ	ជុំ	ទរិន	អត្តលេខ ៥៥៥៩០ រងផ្នែកបែបបទច្រកទ្វារបារិត ន.អន្តោប្រវេសន៍ ក្រ.ម.ផ
១១-លោក	ខេង	សុធា	អនុប្រធានការិយាល័យរដ្ឋបាល មន្ទីរដែនដីសុរិយោដីសំណង់
១២-លោក	ហ៊ី	ធារិត	មន្ត្រីទីចាត់ការរដ្ឋបាល សាលាខេត្តបន្ទាយមានជ័យ
១៣-អនុសេនីយ៍ទោ	សាំង	គីមស៊ា	អត្តលេខ ២២៧២២ នាយផ្នែកសន្តិសុខ អធិការដ្ឋាននគរបាល ស្រុកមង្គលបូរី
១៤-អនុសេនីយ៍ទោ	ម៉ាន់	ចន្ទសារ	អត្តលេខ ៦២៣១៣ នាយផ្នែកយុត្តិធម៌ អធិការដ្ឋាននគរបាល ស្រុកមង្គលបូរី

ខ-មេដាយប្រាក់ការងារ:

១-អនុសេនីយ៍ត្រី ឌី ឈាតហេង អត្តលេខ ៤៤៥៣៩ នាយរងផ្នែកយុត្តិធម៌ អធិការដ្ឋាននគរបាល ស្រុកមង្គលបូរី

២-អនុសេនីយ៍ត្រី ឈឹម សោភនោ អត្តលេខ ០២០៣៤៣ នាយរងផ្នែកស្ថិតិ អធិការដ្ឋាននគរបាល ស្រុកមង្គលបូរី

៣-លោក មិន និមល ប្រធានការិយាល័យ សាលាស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

៤-លោក សុខ ឆន នាយកអង្គការអភិវឌ្ឍន៍ ធនធានមនុស្ស ខេត្តបន្ទាយមានជ័យ

៥-លោក យិម សារី ស្មៀនឃុំ ចំណោម ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

៦-លោក នង ភ្លៀប ស្មៀនឃុំ អូរប្រាសាទ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

៧-លោក គន់ សុវណ្ណា ស្មៀនឃុំ ភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

៨-លោក ទូច ឃិញ ស្មៀនឃុំ បត់ត្រង់ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

៩-លោក តុង រួម ស្មៀនឃុំ សឿ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

១០-លោក យិម គីមសឿត ស្មៀនឃុំ គយម៉ែង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

១១-លោក ចាន់ ម៉ុនធឿន ស្មៀនឃុំ តាឡំ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

គ-មេដាយសំរិទ្ធការងារ:

១-លោក គី សុភារ៉ា ស្មៀនឃុំ ស្រះរាំង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

២-លោកស្រី អោ រចនា មន្ត្រី សាលាស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

៣-អនុសេនីយ៍ត្រី ស៊ូ សុផល អត្តលេខ ០២០៣៤៤ នាយរងប៉ុស្តិ៍រដ្ឋបាលឃុំ អធិការដ្ឋាននគរបាល ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ

៤-លោក គី សុភារម្យ មន្ត្រី សាលាស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១៧៣ . អនក្រ . បក

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០៩៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

សម្រេច

មាត្រា ១ : តែងតាំងលោក **ឯក ស៊ីវដេ** ជាសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧ ស.ស.រ

សេចក្ដីសម្រេច

ស្ដីពី

ការបង្កើតគណៈកម្មការ និងអនុគណៈកម្មការទទួលបន្ទុកដោះស្រាយករណីឧបទ្ទវហេតុ ដែលបានកើតឡើងនារាត្រីថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១០ នៃព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប សំពះព្រះខែ និងអកអំបុក នៅលើស្ពានពេជ្រ នៃតំបន់កោះពេជ្រ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់នៃការងារ

សម្រេច

ប្រការ ១.-

ត្រូវបានបង្កើតគណៈកម្មការទទួលបន្ទុកដោះស្រាយករណីឧបទ្ទវហេតុ ដែលបានកើតឡើងនាត្រីថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១០ នៃព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប សំពះព្រះខែ និងអកអំបុក នៅលើស្ពានពេជ្រ នៃតំបន់កោះពេជ្រ ដែលមានសមាសភាពដូចខាងក្រោម ៖

១. ឯកឧត្ដម	**សុខ អាន**	ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី	ប្រធាន
២. ឯកឧត្ដម	**ញឹម វណ្ណដា**	ទេសរដ្ឋមន្ត្រី អនុប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ	អនុប្រធាន
៣. ឯកឧត្ដម	**ឱម យ៉ិនទៀង**	ទេសរដ្ឋមន្ត្រី អនុប្រធានគណៈកម្មាធិការជាតិប្រឆាំងអំពើពុករលួយ	អនុប្រធាន
៤. ឯកឧត្ដម	**អ៊ិត សំហេង**	រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	អនុប្រធាន

៥. ឯកឧត្តម	វង សូត	រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	អនុប្រធាន
៦. ឯកឧត្តម	ម៉ម ប៊ុនហេង	រដ្ឋមន្ត្រីក្រសួងសុខាភិបាល	អនុប្រធាន
៧. ឯកឧត្តម	កែប ជុតិមា	អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ	អនុប្រធាន
៨. ឯកឧត្តម	ខៀវ កាញារីទ្ធ	រដ្ឋមន្ត្រីក្រសួងព័ត៌មាន	សមាជិក
៩. ឯកឧត្តម	អ៊ុក រ៉ាប៊ុន	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
១០. ឯកឧត្តម	ព្រុំ សុខា	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	សមាជិក
១១. ឧកញ៉ា	ពុង ខៀវសែ	អគ្គនាយកក្រុមហ៊ុន OCIC	សមាជិក
១២. ឯកឧត្តម	នេត សាវឿន	អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ	សមាជិក
១៣. ឯកឧត្តម	សៅ សុខា	អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក
១៤. លោកជំទាវ	ពុំ ចន្ទីនី	អគ្គលេខាធិការកាកបាទក្រហមកម្ពុជា	សមាជិក។

ប្រការ ២.-

គណៈកម្មការទទួលបន្ទុកដោះស្រាយករណីឧបទ្ទវហេតុ មានភារកិច្ចដោះស្រាយការងារបន្ទាន់ចំពោះមុខដូចខាងក្រោម ÷

- ចាត់ចែងសង្គ្រោះបន្ទាន់ជនរងគ្រោះ
- រៀបចំចាត់ចែងបញ្ជូនសពដល់គ្រួសារ ដើម្បីរៀបចំពិធីបុណ្យតាមប្រពៃណី
- រៀបចំចាត់ចែងឧបត្ថម្ភដល់គ្រួសារសព
- ធ្វើកោសល្យវិច្ច័យសាកសព និងស៊ើបអង្កេតអំពីមូលហេតុនៃឧបទ្ទវហេតុ
- រាយការណ៍អំពីករណីឧបទ្ទវហេតុជូនប្រមុខរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

ប្រការ ៣.-

ត្រូវបានបង្កើតអនុគណៈកម្មការដោះស្រាយការងារបន្ទាន់លើករណីឧបទ្ទវហេតុ ដែលបានកើតឡើងនាពេលរាត្រីថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១០ នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក នៅលើស្ពានពេជ្រ នៃតំបន់កោះពេជ្រ ដែលមានសមាសភាពដូចខាងក្រោម ÷

១. ឯកឧត្តម	អ៊ិត សំហេង	រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	ប្រធាន
២. ឯកឧត្តម	វង សូត	រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	អនុប្រធាន
៣. ឯកឧត្តម	មិន ឃិន	រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា	អនុប្រធាន
៤. ឯកឧត្តម	ប៉ា សុជាតិវង្ស	អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ និងជាប្រធានកាកបាទក្រហមរាជធានីភ្នំពេញ	សមាជិក
៥. ឯកឧត្តម	គង់ អ៊ូក	អនុប្រធានជាតិកាយរិទ្ធកម្ពុជា	សមាជិក
៦. ឯកឧត្តម	សោម អួន	ជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៧. ឯកឧត្តម	ចៅ វាសនា	ជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៨. លោក	វង្ស សុវណ្ណ	ប្រធានសហភាពសហព័ន្ធសហជីពជាតិកម្ពុជា	សមាជិក។

ប្រការ ៤.-

អនុគណៈកម្មការដោះស្រាយការងារបន្ទាន់លើករណីឧបទ្ទវហេតុ មានភារកិច្ចដូចខាងក្រោម ÷

- ជួយសង្គ្រោះដល់ជនរងគ្រោះ

- ចាត់ចែងប្រគល់សពដល់គ្រួសារ ដើម្បីរៀបចំពិធីបុណ្យតាមប្រពៃណី
- ចាត់ចែងឧបត្ថម្ភដល់គ្រួសារសព
- រាយការណ៍អំពីលទ្ធផលការងារជូនគណៈកម្មការទទួលបន្ទុកដោះស្រាយករណីឧបទ្ទវហេតុ
- បំពេញភារកិច្ចផ្សេងទៀត ដែលគណៈកម្មការទទួលបន្ទុកដោះស្រាយករណីឧបទ្ទវហេតុប្រគល់ជូន។

ប្រការ ៥.-

ត្រូវបានបង្កើតអនុគណៈកម្មការស៊ើបអង្កេតករណីឧបទ្ទវហេតុ ដែលបានកើតឡើងនាពេលរាត្រីថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១០ នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក នៅលើស្ពានពេជ្រ នៃតំបន់ កោះពេជ្រ ដែលមានសមាសភាពដូចខាងក្រោម ÷

១. ឯកឧត្តម **ព្រុំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ប្រធាន
២. ឯកឧត្តម **សុខ ផល** អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អនុប្រធាន
៣. ឯកឧត្តម **ថោង លឹម** ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ សមាជិក
៤. ឯកឧត្តម **ឌៀខ សារុន** មេបញ្ជាការរង នៃបញ្ជាការដ្ឋានអង្គរក្ស សមាជិក
៥. ឯកឧត្តម **ម៉ក់ ជីតូ** ប្រធាននាយកដ្ឋានកណ្តាលនគបាលយុត្តិធម៌ នៃអគ្គស្នងការដ្ឋាន នគរបាលជាតិ សមាជិក
៦. ឯកឧត្តម **ឆៃ ស៊ីណារិទ្ធ** ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង នៃអគ្គស្នងការដ្ឋាន នគបាលជាតិ សមាជិក
៧. ឯកឧត្តម **សៅ សម្បត្តិ** នាយរងការិយាល័យព្រហ្មទណ្ឌ នៃកងរាជអាវុធហត្ថ លើផ្ទៃប្រទេស សមាជិក
៨. ឯកឧត្តម **ហុខ ខិណុល** ស្នងការនៃស្នងការដ្ឋានព័ត៌មាន និងសន្តិសុខ នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
៩. លោក **អ៊ុយ សុធា** មេបញ្ជាការរងកម្លាំងពិសេសវាយលុកភេរវកម្ម នៃ លេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម សមាជិក
១០. លោក **សម្បត្តិ ហ៊ីណា** អនុប្រធាននាយកដ្ឋានចារកម្ម និងស៊ើបអង្កេត នៃ លេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម សមាជិក។

ប្រការ ៦.-

អនុគណៈកម្មការស៊ើបអង្កេតករណីឧបទ្ទវហេតុ មានភារកិច្ចដូចខាងក្រោម ÷

